

សូមជំរាបបងប្អូនឱ្យបានជ្រាបថា លោក **សម រង្ស៊ី** នឹងអញ្ជើញមក ក្រុង **សាន់ ហូសេ** ក្នុងបំណងជួបសំណេះសំណាលជាមួយបងប្អូន។ បងប្អូនបានដឹងហើយថា លោក សម រង្ស៊ី បានធ្វើការងារលះបង់កំលាំងកាយកំលាំងចិត្ត ដើម្បីការពារជនស្លូតត្រង់ក្រីក្រ លើកតម្កើងកម្មករ និងហ៊ានឈរការពារជនរងគ្រោះដែលបាត់បង់ដី និង ត្រូវគេបណ្តេញចេញដោយបង្ខំ។

ថ្មីៗនេះ ដីស្រែរបស់បងប្អូនខ្មែរនៅខេត្ត ស្វាយរៀង ត្រូវបាត់បង់ដោយសារយួនបង្ខិតបង្គោលព្រំដែនចូលទៅក្នុងដីស្រែរបស់គាត់។ លោក សម រង្ស៊ី បានបញ្ចេញសកម្មភាពរួមជាមួយបងប្អូនជាម្ចាស់ដីស្រែ បានដកបង្គោលចេញពីដីស្រែទាំងនោះ។ សកម្មភាពនេះបែជាធ្វើឱ្យសភាជាតិខ្មែរ សម្រេចដកអភ័យឯកសិទ្ធិសភារបស់លោកទៅវិញ។ ហើយតុលាការសាលាខេត្តស្វាយរៀង បានសម្រេចដាក់ទោសលោក សម រង្ស៊ី ឱ្យជាប់គុក ២ ឆ្នាំ។ នៅពេលលោកធ្វើនិរទេសដល់ប្រទេសបារាំង លោក សម រង្ស៊ី បានប្រឈមមុខនឹងការកាត់ទោសបន្ថែម ដោយសារការលាតត្រដាងបញ្ហាព្រំដែនខ្មែរ ។

បញ្ហាព្រំដែន ជាប្រធានបទដ៏ក្តៅគគុក ដូចជាបញ្ហាប្រាសាទព្រះវិហារជាដើម ដែលពួកសៀម ធ្វើការទាមទារនោះ។ ព្រឹត្តិការណ៍នៃរឿងបញ្ហាព្រំដែននេះ នៅតែបន្តដល់សព្វថ្ងៃ ។ លោក **ស៊ាន ប៉េងសែ** អតីតជារដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និង ជាអ្នកឯកទេសខាងព្រំដែនខ្មែរដ៏ល្បីល្បាញ នឹង រួមមកជាមួយ លោក សម រង្ស៊ី ដើម្បីជួយបំភ្លឺបញ្ហាព្រំដែន ដល់បងប្អូន។

បងប្អូនខ្មែរយើងខ្លះបានទៅដល់ស្រុកខ្មែរ មួយចំនួនថា ប្រទេសយើងមានការលូតលាស់ច្រើន រីឯអ្នកខ្លះវិញថា អំពើពុករលួយ បញ្ហាគិបក្សនិយម ការគាបសង្កត់បំបិទសិទ្ធិសេរីភាព អំពើអយុត្តិធម៌ និងការរួសទាញយកដីធ្លីដោយខុសច្បាប់ នៅតែមានពាសពេញលើផ្ទៃប្រទេស។ លោក សម រង្ស៊ី និង លោក ស៊ាន ប៉េងសែ នឹងមកបំភ្លឺការពិត ជូនដល់បងប្អូន។

សូមគោរពអញ្ជើញបងប្អូន មកចូលរួមទទួលស្វាគមន៍ លោក សម រង្ស៊ី និង លោក ស៊ាន ប៉េងសែ តាមពេលវេលា និង ទីកន្លែង តាមការកំណត់ដូចខាងក្រោម៖

# សេចក្តអញ្ជើញ

## Sunday, May 30, 2010
## 11am - 3pm

## Wat Khemara Rangsey
1594 Cunningham Ave,
San Jose, CA 95122









ទំនាក់ទំនង៖

លោក លឹម ហ៊្វីលិព (408) 439-7564

អ្នកស្រី បៃ សុផានី (408) 882-7645

លោក ឡោ ឡៃស្វ (408) 923-6283

លោក កស់ ប៊ុនកន (408) 799-0648